រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីកូ(ភ្នំពេញ) ខូអិលធីឌី

SHEICO(Phnom Penh)CO.,LTD

អាសយដ្ឋាន ផ្លូវជាតិលេខ៣ ភូមិ ស្រែញរ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ

---

# កិច្ចព្រមព្រៀង
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
## រវាង

នាយករោងចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

កម្មវត្ថុ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន៣៨៨នាក់រយះពេល៣២ថ្ងៃ។

យោង៖ មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិសេដ្ឋកិច្ចសកល លេខៈ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃពុធ ៩រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង១០និង០០នាទី មានកិច្ចប្រជុំនៅរោងចក្រ ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី

បានព្រមព្រៀង និងឯកភាពគ្នាដូចខាងក្រោម៖

១- ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកដេរ ផ្នែកពិនិត្យ ផ្នែកតុកាត់ ផ្នែកបោះពុម្ព ផ្នែកជាងម៉ាស៊ីន សរុបចំនួន៣៨៨ នាក់ រយះពេល៣២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមិថុនា រហូតដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣។

២- នាយករោចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត បានព្រមព្រៀងផ្តល់ប្រាក់ចំនួន៤៥ដុល្លាអាមេរិក ពីរោងចក្រ

៣- ចូលធ្វើការវិញនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៣។

កំណត់ហេតុនៃកិច្ចព្រមព្រៀងនេះ បានចប់សព្វគ្រប់នៅថ្ងៃដដែលវេលាម៉ោង១០និង៣០នាទី ក្រោមបរិយាកាសរីករាយ ឯកភាពគ្នា និងភាពស្និទ្ធស្នាលក្រៃលែង។

ភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣

ស្នាមមេដៃស្តាំសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

ហត្ថលេខា និងត្រាម្ចាស់ ឬនាយក

SHEICO (PHNOM PENH) CO.,LTD. HR
KINGDOM OF CAMBODIA

Huang Wei Chih